ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា និងទិសដៅការងារខែឧសភា ឆ្នាំ២០២៥

នៅក្នុងខែមេសា ឆ្នាំ២០២៥ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកប ដោយស្មារតីទទួលខុសត្រូវខ្ពស់ ទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥

### ១-មុខងារនីតិកម្ម

- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បី៖
  - ១- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។
  - ២- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភា លើកទី៣ នីតិកាលទី៥ និង
  - ៣- ផ្សេងៗ។
- បានរៀបចំបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដើម្បីស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។

### ២-មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការនានារបស់ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា៖
  - ❖ គណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយធនាគារជាតិនៃកម្ពុជា ដឹកនាំដោយ **ឯកឧត្តម ស៊ុំ សន្និសិទ្ធ** ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ដើម្បីឈ្វេងយល់

អំពីវឌ្ឍនភាព និងបញ្ហាប្រឈម ក្នុងវិស័យធនាគារ ជាពិសេសផ្តោតលើវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅធនាគារជាតិនៃកម្ពុជា និង

❖ គណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជួបពិភាក្សាការងារជាមួយ **ឯកឧត្តមនាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ និងទិសដៅការងារបន្តរបស់ក្រសួងឆ្នាំ២០២៥ នៅទីស្តីការក្រសួងការពារជាតិ។

## ៣-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖ បានអនុញ្ញាតឱ្យសមាជិកព្រឹទ្ធសភាមកពីគណបក្សធន្ទះខ្មែរ ចំនួន៣រូប រួមមាន **ឯកឧត្តម សុក ហាច ឯកឧត្តម សេង ម៉ារឌី** និង**ឯកឧត្តម គង់ មុនីកា** ចូលជួបសម្តែងការគួរសម នៅវិមានព្រឹទ្ធសភា។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងជាព្រះរាជាធិបតីដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅខេត្តសៀមរាប។
  - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងថ្វាយគ្រឿងសក្ការបូជា ចំពោះព្រះអង្គចេកព្រះអង្គចម និងលោកយាយទេព បន្ទាប់ពីព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា។
  - បានអញ្ជើញទទួលព្រះរាជដំណើរមាតុភូមិនិវត្តន៍របស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ បន្ទាប់ពីព្រះអង្គយាងពិនិត្យព្រះរាជសុខភាព នៅសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
  - បានអញ្ជើញជាអធិបតីក្នុងពិធីបុណ្យ ពិធីដង្ហែ ពិធីបញ្ចុះសព និងពិធីបុណ្យទក្ខិណានុប្បទាន ខួបគម្រប់៧ថ្ងៃ និង១០០ថ្ងៃ ឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងត្រូវជាបងប្រុសបង្កើតរបស់ **សម្តេចតេជោ** នៅសង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ និង
  - បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមគ្រួសាររបស់ចៅស្រី **ស៊ុន ស្រីតី** រស់នៅភូមិថ្មី ឃុំចំបក់ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ នៅភូមិគ្រឹះតាខ្មៅ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖ បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងចូលរួមបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖
  - បានអនុញ្ញាតឱ្យ ឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិកាព្រឹទ្ធសភា ចូលជួបសម្តែងការគួរសម និងគោរពជូនពរ ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា និងលោកជំទាវ ក្នុងឱកាសពិធីអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ នៅបន្ទប់ទទួលភ្ញៀវឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា និង
  - បានអនុញ្ញាតឱ្យឯកឧត្តមប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងថ្នាក់ដឹកនាំខុទ្ទកាល័យសម្តេចតេជោ អញ្ជើញចូលជួបសម្តែងការគួរសម និងគោរពជូនពរ ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា និងលោកជំទាវ ក្នុងឱកាសពិធីអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ នៅបន្ទប់ទទួលភ្ញៀវឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា។
- បេសកកម្មក្នុងប្រទេស៖
  - បានអញ្ជើញចុះពិនិត្យការដ្ឋានសាងសង់ផ្លូវ ស្ពាន ដំណាក់កាលទី១ និងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋ នៅឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល និង
  - បានចាត់ **ឯកឧត្តម ជឹម លាវ** សមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ រួមទាំងទីប្រឹក្សាផ្ទាល់ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តរបស់ក្រុមហ៊ុន Laboratoire Bioderma សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនដល់បងប្អូនប្រជាពលរដ្ឋ នៅស្រុកស្រីសន្ធរ ស្រុកព្រៃឈរ និងស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប និង
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្តអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ និងបានប្រគេនចង្ហាន់ ទេយ្យទាន និងគ្រឿងបរិក្ខារប្រគេនដល់ព្រះសង្ឃ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខន្ធរ៉ា អនុប្រធានទី២ព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំនានា៖
  - បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងចូលរួមបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំជាមួយប្រធានគណៈកម្មការទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ និងក្រុមសមាជិកាព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ខុទ្ទកាល័យ ប្រចាំត្រីមាសទី១ ឆ្នាំ២០២៥ និងទិសដៅការងារបន្ត នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- បដិសណ្ឋារកិច្ចភ្ញៀវជាតិ៖ បានអនុញ្ញាតប្រគេន **ព្រះភិក្ខុមនាបោ ប៊ុត សុខគា** ព្រះធម្មធរអនុគណស្រុក និមន្តជួបនៅសាលប្រជុំខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបួងសួងចម្រើនសេចក្ដីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប និង
  - បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីសូត្រមន្តចម្រើនព្រះបរិត្តអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ និងបានប្រគេនចង្ហាន់ ទេយ្យទាន និងគ្រឿងបរិក្ខារប្រគេនដល់ព្រះសង្ឃ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
  - បានអញ្ជើញចូលរួមពិធីបុណ្យផ្កា នៅវិទ្យាល័យព្រះស៊ីសុវត្ថិ និង
  - បានអញ្ជើញចូលរួមពិធីអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ របស់សមាគមអតីតនិស្សិតជប៉ុន នៅ Oakwood Premier Phnom Penh។

❖ **សមាជិក សមាជិកាព្រឹទ្ធសភា៖**

- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីបួងសួងចម្រើនសេចក្ដីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណា ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប។
- បានអញ្ជើញជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU)

លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសាធារណរដ្ឋអ៊ូសបេគីស្ថាន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- បានអញ្ជើញចូលរួមចុះពិនិត្យការដ្ឋានសាងសង់ផ្លូវ ស្ពាន ដំណាក់កាលទី១ និងពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៅឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល។
- បានអញ្ជើញចូលរួមពិធីសូត្រមន្តអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម អ៊ុច បូរិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដើម្បីប្រោះព្រំសុំសេចក្តីសុខ សិរីសួស្តី ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅវិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្តីពី "បម្រែបម្រួលប្រជាសាស្ត្រ និងជំងឺមិនឆ្លង៖ គោលនយោបាយ ឆ្លើយតបបញ្ហាប្រឈម សម្រាប់ប្រជាជនសកម្ម និងយុវជន" នៅវិមានរដ្ឋសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំស្តីពី បូកសរុបលទ្ធផលការងារចន្លោះសម័យប្រជុំ និងការពង្រឹងគណនេយ្យភាពសមាជិកព្រឹទ្ធសភា ជាមួយអង្គបោះឆ្នោត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត ធន់ វ៉ាឡូនា** អនុប្រធានទី២ព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី "ការកៀរគរឆន្ទៈនយោបាយក្នុងការអនុវត្តរបៀបវារៈស្តីពី ស្ត្រី សន្តិភាព និងសន្តិសុខនៅកម្ពុជា" ក្រោមអធិបតីភាពរបស់ **លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅសណ្ឋាគារណូវ៉ូតែលភ្នំពេញ។
- បានអញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មការ និងអនុគណៈកម្មការរៀបចំទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៥ និងខួបលើកទី៧០នៃកាកបាទក្រហមកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **លោកជំទាវបណ្ឌិត ពេជ្រ ចន្ទមុន្នី ហ៊ុនម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា និងជាប្រធានគណៈកម្មការរៀបចំទិវា ៨ ឧសភា នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា។
- បានអញ្ជើញជាវាគ្មិនក្នុងកម្មវិធីធ្វើបទបង្ហាញស្តីពី "រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា" ជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប សរុបចំនួន១១៤នាក់ នៅសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។
- បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ **ចំនួន១០លើក** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី**នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖

  ១/ ពិធីប្រកាសជាផ្លូវការ និងសម្ពោធដាក់ឱ្យអនុវត្តនូវ "កម្មវិធីពិសេសជំរុញការវិនិយោគក្នុងខេត្តទាំងបួន នៅភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៥-២០២៨"។

  ២/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមជ្ឈមណ្ឌលទំនើបកម្មមូលដ្ឋានសមុទ្ររាម និងមជ្ឈមណ្ឌលភស្តុភារ និងហ្វឹកហ្វឺនរួមគ្នាកម្ពុជា-ចិន ផែរាម។

  ៣/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារស្នាក់នៅ អគារសិក្សា និងសមិទ្ធផលនានា

នៅវិទ្យាស្ថានបញ្ញាការសេនាធិការ។

៤/ ពិធីពិសាអាហារស្រោយបួសខែរ៉ាម៉ាឌននៃសាសនាឥស្លាមកម្ពុជាលើកទី៩ ឆ្នាំ២០២៥។

៥/ ពិធីបើកព្រឹត្តិការណ៍អង្គរសង្ក្រាន្ត លើកទី១១ ឆ្នាំ២០២៥។

៦/ ពិធីសម្ពោធអគារសិក្សា អគារស្នាក់នៅរបស់គ្រូបង្រៀន ទីចាត់ការ និងអគារកាត់ដេរ នៅវិទ្យាល័យ ហ៊ុនសែន វាលវេញ។

៧/ ពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការកំពង់ផែទេសចរណ៍អន្តរជាតិកំពត។

៨/ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤ និងទិសដៅការងារឆ្នាំ២០២៥ របស់ក្រសួងមុខងារសាធារណៈ។

៩/ ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវស្ពានអាកាស "មរតកតេជោ" នៅចំណុចប្រសព្វរវាងមហាវិថី សម្តេចតេជោហ៊ុនសែន មហាវិថីព្រះមុនីវង្ស និងមហាវិថីកងយោធពលខេមរភូមិន្ទ និង

១០/ពិធីសម្ពោធបើកឱ្យប្រើប្រាស់ជាផ្លូវការផ្លូវជាតិលេខ៧១សេ ប្រវែងសរុប១១៤,៩៩ គីឡូម៉ែត្រ តភ្ជាប់ខេត្តត្បូងឃ្មុំ-ខេត្តកំពង់ចាម តម្លៃ១៣៣លានដុល្លារ ដោយប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

❖ ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ នៅមូលដ្ឋាន ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា **ចំនួន១០០លើក** ព្រមទាំងបានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ **ចំនួន២២៥លើក**។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាៈ

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបានៈ

- អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងចូលរួមបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
- អញ្ជើញចូលរួមព្រះរាជពិធីបួងសួងចម្រើនសេចក្តីសុខ ជូនដល់ព្រះរាជាណាចក្រកម្ពុជា នៅមុខប្រាសាទអង្គរវត្ត ខេត្តសៀមរាប ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា និង
- អញ្ជើញប្រគល់អំណោយជូន **លោក ស៊ូ សារ៉ាង** នាយកប្រតិបត្តិនៃសមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ នៅវិមានព្រឹទ្ធសភា។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និង**ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីជប់លៀង ក្នុងឱកាសខួបលើកទី១៥ឆ្នាំ របស់សណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា នៅភោជនីយដ្ឋាន La Coupole។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមពិធីសូត្រមន្តចម្រើនព្រះបរិត្តអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា នៅសាលពិសេស៣ វិមានព្រឹទ្ធសភា និង
  - អញ្ជើញចូលរួមពិធីសូត្រមន្តចម្រើនព្រះបរិត្តអបអរសាទរសង្ក្រាន្តឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅសាលអង្គរជំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

- **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក ប៉ូវ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូររិទ្ធ** អនុប្រធានទី១ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅសាធារណរដ្ឋអ៊ូសបេគីស្ថាន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
  - អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **លោកស្រី ពេជ្រ សូភី** ភរិយា **លោក ព្រាប មុនី** ចៅសង្កាត់ព្រែកលៀប នៅគេហដ្ឋាននៃសព ស្ថិតនៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម អោក ប៉ូវ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញនាំយកថវិការបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន** ប្រធានកាកបាទក្រហមកម្ពុជា ជូនក្រុមគ្រួសារសព **ឯកឧត្តម មួង ប៉យ** សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា ព្រមទាំងបានចូលរួមរៀបចំចាត់ចែងពិធីបុណ្យសពតាមប្រពៃណីជាតិ នៅគេហដ្ឋាននៃសព ស្ថិតនៅក្រុងបានលុង ខេត្តរតនគិរី។

- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភាបាន៖
  - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន១លើក និងចូលរួមបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន១លើក។
  - អញ្ជើញចូលរួមពិធីដង្ហែ និងបញ្ចុះសព **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើតរបស់ **សម្តេចតេជោ** នៅវត្តចន្ទបុរីវង្ស សង្កាត់សំរោង ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ។
  - អញ្ជើញចូលរួមអម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម មួង ប៉យ** សមាជិក

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតនៅក្រុងបានលុង ខេត្តរតនគិរី និង

- អញ្ជើញចូលរួមកិច្ចប្រជុំការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងពិធីផ្សេងៗ ចំនួន២លើក។

- សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក) នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចូលជួបសម្តែងការគួរសម និងជូនពរ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម អោក បូរ៉ា** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩ នៅវិមានព្រឹទ្ធសភា។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ និងគោរពជូនឥស្សរជនជាន់ខ្ពស់ មន្ត្រីរាជការ និងប្រជាពលរដ្ឋទូទាំងប្រទេស ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរព្រះរាជគុណ និងអំណរគុណរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី**នៃព្រះរាជាណាចក្រកម្ពុជា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងជូនឥស្សរជនជាន់ខ្ពស់ និងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ដែលបានសព្វព្រះរាជហឫទ័យប្រទានព្រះរាជសារចូលរួមរំលែកមរណទុក្ខ និងផ្ញើសារចូលរួមរំលែកទុក្ខ សពរបស់ **ឯកឧត្តមអ្នកឧកញ៉ាឧត្តមមេត្រីវិសិដ្ឋ ហ៊ុន សាន** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាបងប្រុសបង្កើតរបស់ **សម្តេចតេជោ**។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា គោរពជូន **ឯកឧត្តម ឯក សំអុល** ដែលត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់សព្វព្រះរាជហឫទ័យ ត្រាស់បង្គាប់តែងតាំងជា "ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា"។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុ គោរពជូន៖
    - **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ីម កា** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។
    - **ឯកឧត្តម មាស សុភា** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង
    - **ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
    - **លោកជំទាវ ស៊ី ជិប** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តម មួង ប៉យ**

សមាជិកក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងជាសមាជិកគណៈកម្មការទី៤ ព្រឹទ្ធសភា។

- **លោកជំទាវ ស៊ុំ សុភី** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ព្រំ ម៉ល់** សមាជិកពេញសិទ្ធិរាជបណ្ឌិត្យសភាកម្ពុជា ទីប្រឹក្សារាជរដ្ឋាភិបាល និងជាអតីតប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ និង
- **ឯកឧត្តម តាន់ ហ្សង់-ហ្វ្រង់ស័រ** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **លោកស្រី អាំង គីមឈរ**។

- បានរៀបចំតុបតែងលម្អសង្ក្រាន្ត ការសម្តែងរបាំត្រុដិ ព្រមទាំងបានរៀបចំពិធីសូត្រមន្តចម្រើនព្រះបរិត្ត និងវណ្តាប់ទទួលទេវតាឆ្នាំថ្មី នៅវិមានព្រឹទ្ធសភា ក៏ដូចជាអាហារសាមគ្គី ក្នុងឱកាសអបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ២៥៦៩ និង
- បានទទួលពាក្យបណ្តឹង ចំនួន៧បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង-ស្ថាប័ន និងខេត្តពាក់ព័ន្ធ ចំនួន៦បណ្តឹង បញ្ជូនពាក្យបណ្តឹងទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ចំនួន១បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចំនួន១បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន៩បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន១០បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន២បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន៨បណ្តឹង និងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ចំនួន២បណ្តឹង។

## ៤-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា៖**

- បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖
  - បានអនុញ្ញាតឱ្យភ្ញៀវអន្តរជាតិ ចូលជួបសម្តែងការគួរសម ចំនួន៣លើក រួមមាន៖
    - ១/ **ឯកឧត្តម ស៊ី ជិនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន នៅវិមានសន្តិភាព។
    - ២/ **លោកជំទាវ ផែថងថាន ស៊ីណាវ៉ាត្រ** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃឡង់ដ៍ នៅវិមានព្រឹទ្ធសភា និង
    - ៣/ **ព្រះអង្គម្ចាស់** Guillaume Jean Joseph Mari រជ្ជទាយាទនៃបូរីក្សេត្រលុចសំបួ នៅវិមានព្រឹទ្ធសភា។
- បេសកកម្មក្រៅប្រទេស៖
  - បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមខួបអនុស្សាវរីយ៍លើកទី៥០ នៃទិវារំដោះភាគខាងត្បូង និងបង្រួបបង្រួមជាតិវៀតណាម នៅទីក្រុងហូជីមិញ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ដោយក្នុងឱកាសទស្សនកិច្ចនោះ **សម្តេចតេជោ** បានជួបពិភាក្សាការងារទ្វេភាគីជាមួយ៖
    - ១/ **ឯកឧត្តម តូ ឡឹម** អគ្គលេខាធិការនៃគណៈកម្មាធិការបញ្ញើមបក្សកុម្មុយនីស្តវៀតណាម។

២/ **ឯកឧត្តម ផាម មិញជីញ** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និង
៣/ **ឯកឧត្តម ជិន ថាញ់មិន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

- សកម្មភាពចូលរួមពិធីផ្សេងៗ៖
    - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ស្តេចយាងទទួលបដិសណ្ឋារកិច្ចស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមាននៃការអញ្ជើញមកដល់របស់ **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឱកាសដែលឯកឧត្តមអញ្ជើញបំពេញទស្សនកិច្ចផ្លូវរដ្ឋ រយៈពេល២ថ្ងៃ នៅព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
    - បានអញ្ជើញដង្ហែ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា ក្នុងព្រះរាជពិធីលៀងសាយភោជន៍ផ្លូវរដ្ឋជូន **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រះបរមរាជវាំង និង
    - បានអញ្ជើញជូនដំណើរ **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ធ្វើមាតុភូមិនិវត្តន៍ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី១ព្រឹទ្ធសភា៖**

- សកម្មភាពចូលរួមកិច្ចប្រជុំ៖
    - បានដឹកនាំកិច្ចប្រជុំគណៈប្រតិភូសភាកម្ពុជា ដើម្បីត្រៀមចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងតាស្កិននៃសាធារណរដ្ឋអ៊ូសបេគីស្ថាន នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖
    - ក្នុងនាមជាប្រធានស្តីទីព្រឹទ្ធសភា បានអនុញ្ញាតទទួលជួបពិភាក្សាការងារជាមួយ **ឯកឧត្តម អាណាតូលី បូរ៉ូវីក** ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងទំនាក់ទំនងទ្វេភាគីរវាងកម្ពុជា-រុស្ស៊ី នៅបន្ទប់ទទួលភ្ញៀវឯកឧត្តម។
- បេសកកម្មក្រៅប្រទេស៖
    - បានអញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់សភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា (IPU) លើកទី១៥០ និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមមូលបទ "សកម្មភាពសភាដើម្បីការអភិវឌ្ឍសង្គម និងយុត្តិធម៌" នៅទីក្រុងតាស្កិននៃសាធារណរដ្ឋអ៊ូសបេគីស្ថាន។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
    - បានអញ្ជើញចូលរួមបដិសណ្ឋារកិច្ចស្វាគមន៍ដំណើរទស្សនកិច្ចរបស់ **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន អញ្ជើញមកបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- បានអញ្ជើញចូលរួមក្នុងពិធីជូនដំណើរ **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន ធ្វើមាតុភូមិនិវត្តន៍បន្ទាប់ពីបំពេញទស្សនកិច្ចផ្លូវរដ្ឋ នៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
- បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារការងារពេលល្ងាចជាមួយ **ឯកឧត្តម ហ្វ្រាក់ ផៃឡែត** ឯកអគ្គរដ្ឋទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពង្រឹងទំនាក់ទំនងនៃក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-បារាំង។

❖ **ឯកឧត្តមបណ្ឌិត ឆន់ ខឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា៖**

- បដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិ៖
  - បានអនុញ្ញាតឱ្យតំណាងក្រុមហ៊ុន Metfone ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា និង
  - បានអនុញ្ញាតជូន **សាស្ត្រាចារ្យ ហ៊ីយុន ហុនលី** ប្រធាន THE 4TH WAY INSTITUTE និងជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យជាតិ Kangwon សាធារណរដ្ឋកូរ៉េ ជួបពិភាក្សាអំពីការអភិវឌ្ឍសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសេវាសុខាភិបាល នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។
- សកម្មភាពចូលរួមពិធីផ្សេងៗ៖
  - បានអញ្ជើញពិសាអាហារការងារពេលល្ងាច និងពិភាក្សាការងារជាមួយ **ឯកឧត្តម ឯកអគ្គរដ្ឋទូតជប៉ុន** នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា និង
  - បានអញ្ជើញចូលរួមពិធីខួបអនុស្សាវរីយ៍លើកទី៥០ នៃទិវារំដោះភាគខាងត្បូង និងបង្រួបបង្រួមជាតិវៀតណាម នៅស្ថានទូតសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **លោកជំទាវបណ្ឌិត អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ចូលរួម "មហាសន្និបាតពិភពលោក ឆ្នាំ២០២៥ នៃសហព័ន្ធសន្តិភាពពិភពលោក៖ ការបង្កើតយុគសម័យថ្មីនៃសន្តិភាព និងវិបុលភាព" នៅទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ។

❖ **ឯកឧត្តមបណ្ឌិត ថែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា៖

- បានអញ្ជើញចូលរួមពិសាអាហារការងារពេលល្ងាចជាមួយ **ឯកឧត្តម ដេរិក យីប** ឯកអគ្គរដ្ឋទូតអូស្ត្រាលី នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូត រាជធានីភ្នំពេញ និង
- បានអញ្ជើញចូលរួមកម្មវិធីបើកការតាំងពិព័រណ៍រូបថតក្រោមប្រធានបទ "Tokyo Before/After" នៅសារមន្ទីរព្រះស្រីឦសានវរ្ម័ន។

❖ **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងពិធីពិសាអាហារការងារពេលល្ងាច ជាមួយអគ្គលេខាធិការរដ្ឋសភាបារាំង នៅភោជនីយដ្ឋាន Waterside។

- **ឯកឧត្តម ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ **ឯកឧត្តម យ៉ុងចាង មីន** តំណាងមូលនិធិចែករំលែកសង្គ្រោះជីវិតសកលនៃសាធារណរដ្ឋកូរ៉េ និងគណៈប្រតិភូ ចូលជួបពិភាក្សាការងារ នៅសាលប្រជុំគណៈកម្មការទី១០ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម សេង ម៉ារឌី** សមាជិកគណៈកម្មការទី៩ព្រឹទ្ធសភា បានអញ្ជើញជាអធិបតីនៃសន្និសីទអន្តរជាតិ រៀបចំដោយក្រុមប្រឹក្សាសេរីនិយម និងប្រជាធិបតេយ្យអាស៊ី (CALD) នៅមហាវិទ្យាល័យ Miriam ទីក្រុង Quezon ប្រទេសហ្វីលីពីន និង
- **សម្តេចរាជបុត្រីព្រះអនុជ នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងដង្ហែព្រះរាជសវនាការ **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការទទួលជួប **ឯកឧត្តម ស៊ី ជីនពីង** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន នៅព្រះរាជដំណាក់គន្ធបុប្ផា ព្រះបរមរាជវាំង។

- សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបាន៖
    - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់កម្ពុជា ចូលរួមខួបអនុស្សាវរីយ៍លើកទី៥០នៃទិវារំដោះភាគខាងត្បូង និងបង្រួបបង្រួមជាតិវៀតណាម នៅទីក្រុងហូជីមិញនៃសាធារណរដ្ឋសង្គមនិយមវៀតណាម។
    - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងជំនួបសម្តែងការគួរសម ជាមួយភ្ញៀវអន្តរជាតិនានា នៅវិមានព្រឹទ្ធសភា និងវិមានសន្តិភាព ចំនួន៣លើក និង
    - ទទួលជួប **ឯកឧត្តម សាហារូឌីន អន** ឯកអគ្គរដ្ឋទូតម៉ាឡេស៊ី **ឯកឧត្តម អឺមេនេជីលដូ កូប៉ា ឡូម៉េស** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ និង**លោក ខេនស៊ូកេ ណាហ្គាសេ** អនុប្រធានបេសកកម្មនៃស្ថានឯកអគ្គរដ្ឋទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់លើទំនាក់ទំនងទ្វេភាគីនៃប្រទេស និងស្ថាប័នទាំងពីរ និងការបន្តជំរុញនូវកិច្ចសហប្រតិបត្តិការរវាងសភា និងសភា ឱ្យកាន់តែល្អប្រសើរ និងទទួលបានលទ្ធផលផ្លែផ្កា សម្រាប់ជាប្រយោជន៍រួមនៃប្រទេសទាំងពីរ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការ វិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមអម **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានស្តីទីព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដន** អតីតនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** គោរពជូន **ឯកឧត្តមបណ្ឌិត សនសៃ ស៊ីផាន់ដន** នាយករដ្ឋមន្ត្រី

នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំពោះមរណភាពរបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដន** អតីតនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន៖
    - **លោកជំទាវ ទូន ជេននី អាប់ឌុលឡា** ចំពោះមរណភាពរបស់ **ឯកឧត្តមបណ្ឌិត អាប់ ឌុលឡា អាម៉ាដ ប៉ាដាវី** អតីតនាយករដ្ឋមន្ត្រីទី៥នៃប្រទេសម៉ាឡេស៊ី និង
    - **ដូនជី រ៉ាហ្វាអេឡា ប៉េទ្រីនី** ប្រធានអភិបាលបុរីវ៉ាទីកង់ ចំពោះការសោយទិវង្គតរបស់ **សម្ដេច ប៉ាប ហ្វ្រង់ស៊ីស** ព្រះចៅអធិការនៃទីក្រុងរ៉ូម និងជាប្រមុខព្រះសហគមន៍កាតូលិក។
- បានចាត់ចែងបញ្ជូនសារលិខិតជូនពររបស់ **ឯកឧត្តម** Marc Bernhard MdB សមាជិករដ្ឋសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ គោរពជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា គោរពជូន **ឯកឧត្តម** Marc Bernhard MdB សមាជិករដ្ឋសភាសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ដែលបានផ្ញើសារលិខិតជូនពរ **សម្ដេចតេជោ** ក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ **ឯកឧត្តមបណ្ឌិត ជន់ វឌ្ឍនា** ប្រធានស្ដីទីព្រឹទ្ធសភា គោរពជូន **ឯកឧត្តមបណ្ឌិត សាយសំផន ភូមិវិហាន** ប្រធានរដ្ឋសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចំពោះមរណភាពរបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ ខាំតៃ ស៊ីផាន់ដន** អតីតនាយករដ្ឋមន្ត្រី និងប្រធានរដ្ឋនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតចិន ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស មូលនិធិចិនដើម្បីអភិវឌ្ឍន៍ជនបទ(CFRD) មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) មជ្ឈមណ្ឌលឯកសារច្បាប់កម្ពុជា បណ្ណសារដ្ឋានជាតិ បណ្ណាល័យ និងក្រសួង ស្ថាប័ននានា ដើម្បីសម្របសម្រួលកិច្ចសហប្រតិបត្តិការអន្តរជាតិ ការស្នើសុំអាហារូបករណ៍ រៀបចំវគ្គបណ្ដុះបណ្ដាល ការស្វែងរកកៀរគរជំនួយ ព្រមទាំងការរៀបចំកម្មវិធីផ្សេងៗ។

## ៥-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៥.១-សកម្មភាពការងាររបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមីនា និងទិសដៅការងារខែមេសា ឆ្នាំ២០២៥ នៅសាលសិក្ខាសាលាខាងជើងវិមានព្រឹទ្ធសភា។

## ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានបង្វែរប្រាក់បៀវត្ស ប្រាក់បំណាច់ ប្រចាំខែមេសា ឆ្នាំ២០២៥ និងប្រាក់ឧបត្ថម្ភសម្រាប់ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា មន្ត្រីនគរបាលសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត តាមរយៈប្រព័ន្ធធនាគារ។
- បានបង្វែរប្រាក់ប្រមុខរដ្ឋស្តីទី ប្រាក់សង្គមកិច្ចថ្នាក់ដឹកនាំព្រឹទ្ធសភា ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺមន្ត្រីរាជការ ប្រាក់៧%នៃប្រាក់បៀវត្សមន្ត្រីរាជការបង់ចូលបេឡាសោធននិវត្តន៍ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងប្រាក់ឧបត្ថម្ភមូលនិធិសង្គមកិច្ចមន្ត្រីរាជការ ប្រចាំខែមេសា ឆ្នាំ២០២៥ តាមរយៈប្រព័ន្ធធនាគារ។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣៨សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ៤៧សំណើ។
- បានដោះស្រាយសំណើផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា និងកម្មវិធីផ្សេងៗ ចំនួន២៦សំណើ។
- បានថតចម្លងឯកសារ ចំនួន២,៩៧៧ច្បាប់ ប្រើប្រាស់ក្រដាសអស់ ចំនួន២២,៦៧៦សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅតាមបណ្តាភូមិភាគទាំង៨ ចំនួន ៩៥លើក ស្មើនឹង២១៤នាក់។
- បានរៀបចំបោសសម្អាត តុបតែងលម្អសាល ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន១០លើក ស្មើនឹង៤៥២នាក់។
- បានទទួលលិខិតចូល ចំនួន១,២៣៩ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង-ស្ថាប័នពាក់ព័ន្ធនានា ចំនួន៩២៩ច្បាប់។
- បានផ្ញើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា ចំនួន៣៣ច្បាប់ ស្មើនឹង១៥២នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកា ព្រឹទ្ធសភា ចំនួន៥ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការមានជំងឺ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅរាជធានីភ្នំពេញ និងខេត្តបាត់ដំបង ចំនួន១០នាក់។
- ការងារកែលម្អសួនច្បារ និងបរិស្ថានក្នុងបរិវេណព្រឹទ្ធសភា រួមមាន៖
  - បានកាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន១១លើក។
  - បានតាំងលម្អផ្កាមិថុនា និងផ្កាអ័រគីដេ នៅសួនច្បារខាងមុខសាលពិសេស និងសាលសិក្ខាសាលាខាងជើង វិមានព្រឹទ្ធសភា។

- បានដាំដើមម្លូពណ៌ ដើមផ្លិះសេ នៅខាងមុខអគារនាយកដ្ឋានស្រាវជ្រាវថវិកា និងដាំដើមជ្រៃលាភ នៅសួនច្បារជាប់រោងឡាន ព្រមទាំងបានគាស់ដើមឫស្សីដាំក្នុងផើង នៅខាងមុខអគារកងអង្គរក្ស និង
- បានសម្អាតអនាម័យតាមអគារធ្វើការ និងក្នុងបរិវេណព្រឹទ្ធសភាជាប្រចាំ។

- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា រួមមានៈ
  - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន៧១៤នាក់ (ប្រុស៤២៦នាក់ ស្រី២៨៨នាក់)។
  - បុគ្គលិកជាប់កិច្ចសន្យា ចំនួន៨៧នាក់ (ប្រុស៥២នាក់ ស្រី៣៥នាក់)។
  - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន៤៩២នាក់ (ប្រុស៣០៩នាក់ ស្រី១៨៣នាក់)។
  - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន១២នាក់ និង
  - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន៥នាក់។
- បានធ្វើសេចក្ដីសម្រេច ចំនួន៦ច្បាប់ និងលិខិតបង្គាប់ការ ចំនួន១ច្បាប់។
- បានរៀបចំកិច្ចប្រជុំគណៈកម្មការពិនិត្យ និងវាយតម្លៃដំឡើងថ្នាក់បៀវត្សមន្ត្រីរាជការ និងបានរៀបចំរបាយការណ៍ រួមទាំងព្រឹត្តិបត្រវាយតម្លៃការងារសម្រាប់ការដំឡើងថ្នាក់បៀវត្សមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមវេនជ្រើសរើស និងតាមវេនអតីតភាព សម្រាប់ឆ្នាំ២០២៥។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្ទត់ផ្ទង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន៤ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (កូន ចំនួន៣នាក់) ប្រចាំខែមេសា ឆ្នាំ២០២៥។
- បានរៀបចំវគ្គបណ្ដុះបណ្ដាល ចំនួន៣វគ្គ សិក្ខាកាមចូលរួម ចំនួន៤៣នាក់ នៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រួមមានៈ
  - វគ្គមូលដ្ឋានគ្រឹះភាសាចិន (បន្តជំហាន២)។
  - វគ្គភាសាចិនថ្នាក់បឋម (បន្តជំហាន៩) និង
  - វគ្គភាសាចិនថ្នាក់មធ្យម (បន្តជំហាន៩)។
- បានបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន២នាក់ ចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពី វិក្រឹតការមន្ត្រីជាន់ខ្ពស់ឆ្នាំ២០២៥ នៅសាលាភូមិន្ទរដ្ឋបាល។
- បានធ្វើបច្ចុប្បន្នភាព និងព្រាងនូវកម្រងសំណួរសម្រាប់សិក្សាពីតម្រូវការជំនាញ តាម Google Form ដើម្បីត្រៀមធ្វើផែនការបណ្ដុះបណ្ដាលឆ្នាំ២០២៦។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗនៃវិមានព្រឹទ្ធសភា រួមមានៈ
  - បានប្ដូរអ៊ូតូធំទ្វារអាលុយមីញ៉ូម ក្ដារ M.C និងខាន់បន្ទប់ទឹកបុរស នៅសាលប្រជុំពេញអង្គ និងសាលពិសេស៣។
  - បានជួសជុលកែលម្អផ្នែកខាងលើដំបូលឃ្លាំង និងបន្ទប់ទឹក នៅខាងក្រោយសាលពិសេសលើ។
  - បានប្ដូរពិដាន និងខាត់លាបជញ្ជាំងតាមផ្លូវច្រកចេញ-ចូលទៅក្នុងបន្ទប់ទឹក នៅសាលពិសេសក្រោម។
  - បានក្រាលថ្មម៉ាប នៅអគារក្រហម និងមុខសាលសិក្ខាសាលាខាងជើង។

- បានធ្វើ Logo ប្រមុខរដ្ឋស្តីទី សម្រាប់ដាក់លើ Podium និងបំពាក់នាឡិកាអគ្គិសនី នៅអគារក្រហមព្រឹទ្ធសភា ចំនួន៣គ្រឿង។
- បានប្តូរហ្វុងអក្សរ Background ឈ្មោះរបស់គណៈកម្មការ នៅបន្ទប់ប្រជុំគណៈកម្មការទី១ព្រឹទ្ធសភា និង
- បានបាញ់ថ្នាំដែកសង្កត់ព្រំ នៅខាងមុខសាលប្រជុំពេញអង្គ និងសាលពិសេស ចំនួន១៨៦ដើម។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្តាញទឹក បណ្តាញអគ្គិសនី ត្រួតពិនិត្យជណ្តើរយន្ត កំចាត់សត្វកណ្តៀរ រៀបចំ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន២៣៥គ្រឿង/លើក។
- បានរៀបចំរបាយការណ៍វឌ្ឍនភាពការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា រៀងរាល់ ២សប្តាហ៍ម្តង គោរពជូនថ្នាក់ដឹកនាំព្រឹទ្ធសភា។
- បានសហការជាមួយក្រុមការងារសាងសង់អគារថ្មីនៃព្រឹទ្ធសភា ដើម្បីសិក្សា និងភ្ជាប់បណ្តាញលូអគារថ្មីទៅប្រព័ន្ធលូព្រឹទ្ធសភា។
- បានជម្រះបញ្ជីរថយន្តចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋព្រឹទ្ធសភា ចំនួន៧គ្រឿង។
- បានសហការ និងទំនាក់ទំនងធ្វើស្លាកលេខរថយន្ត ម៉ូតូ ជូនសមាជិកព្រឹទ្ធសភា និងខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន២គ្រឿង។
- បានធ្វើរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធនានា និង
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្តីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥។

### ៥.៣-ការងារសេវាច្បាប់៖

- បានទទួលអនុក្រឹត្យ ប្រកាស សេចក្តីសម្រេច សារាចរ សេចក្តីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន១៥ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានទទួលសេចក្តីព្រាងច្បាប់ពីទីស្តីការគណៈរដ្ឋមន្ត្រី ចំនួន២៤ច្បាប់ ព្រមទាំងបានថ្វាយ និងចែកគ្រប់សមាជិក សមាជិកាព្រឹទ្ធសភា។
- បានរៀបចំឯកសារជំនួយស្មារតីក្នុងកិច្ចដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

និងបើកសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន២លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនលេខាធិការសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ១លើក។
- បានរៀបចំឯកសារជំនួយស្មារតីជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនអង្គប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំលើកទី៣ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន២លើក។
- បានផ្តល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ និងធ្វើរបាយការណ៍ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ព្រមទាំងក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន៤៥២លើក។
- បានប្រគល់ឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុល ដែលបានពិនិត្យ ចុះបញ្ជី និងប្រថាប់ត្រារបស់អង្គភាពប្រឆាំងអំពើពុករលួយជូនសាមីខ្លួន និងអ្នកតំណាង ដើម្បីរក្សាទុក ចំនួន៤ច្បាប់ និង
- បានសម្របសម្រួលផ្ទៀងផ្ទាត់ ចុះបញ្ជី និងបញ្ជូនឯកសារប្រកាសទ្រព្យសម្បត្តិ និងបំណុលទទួលការតែងតាំងថ្មី និងចប់មុខតំណែង ចំនួន២០នាក់។

## ៤.៤-ការងារស្រាវជ្រាវ៖

- បានសិក្សាស្រាវជ្រាវ និងរៀបចំឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន២៥ច្បាប់ រួមមាន៖
    - សេចក្តីព្រាងច្បាប់ស្តីពី ជលផល និង
    - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា ចំនួន២៤ច្បាប់។
- បានសិក្សាស្រាវជ្រាវ និងតាមដានវឌ្ឍនភាពនៃការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយពាក់ព័ន្ធ តាមវិស័យនានា។
- បានសង្ខេបយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា និងលទ្ធផលប្រមូលចំណូលពន្ធក្នុងស្រុក ប្រចាំត្រីមាសទី៤ ឆ្នាំ២០២៤។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ៣១២ព័ត៌មាន និង
- បានបញ្ចូលព័ត៌មាន និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ១២-១៦ ឆ្នាំ២០២៤)។

## ៤.៥-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន១៥លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងបណ្តាញសង្គម ចំនួន៣,០២១លើក។

- បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន៧៨២សកម្មភាព។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃព្រឹទ្ធសភា ចំនួន ១,២៧៣ប្រធានបទ។
- បានអញ្ជើញអ្នកសារព័ត៌មាននៃទូរទស្សន៍ជាតិកម្ពុជា ចូលយកព័ត៌មាន ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្តែងការគួរសម ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ និងកម្មវិធីផ្សេងៗ ចំនួន៣លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១៣លើក។
- បានរៀបចំផលិតទស្សនាវដ្តីព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥។
- បានសិក្សាស្រាវជ្រាវ ចងក្រងព្រឹត្តិបត្រស្តីពី បច្ចេកវិទ្យាព័ត៌មាន ចំនួន៧៨ចំណងជើង។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ ថែទាំ និងជួសជុលឧបករណ៍ សម្ភារ បរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មាន ចំនួន១២២គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា ប្រព័ន្ធប្រជុំនិម្មិត ព្រមទាំងបានរចនាផ្ទាំង Backdrop Background ក្នុងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ចំនួន១៦លើក។
- បានទទួលឯកសារ សៀវភៅច្បាប់ និងសៀវភៅជំនាញផ្សេងៗ ចំនួន៦ក្បាល ព្រមទាំងបានចុះបញ្ជីសៀវភៅ បោះត្រាបិទប័ណ្ណខ្ទី និងសងសៀវភៅ ចំនួន១២ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាមគេហទំព័រ www.elibrary.senate.gov.kh ចំនួន ៧,៦៦២ក្បាល ដែលមានសាធារណជនចូលអាន ចំនួន១,០២៥នាក់ (ដោយគិតត្រឹមខែមេសា ឆ្នាំ២០២៥) និង
- បានទទួលឯកសារពីអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងបានរៀបចំចាត់ថែងតម្កល់រក្សាទុកឯកសារនៅបណ្ណសារដ្ឋាន ដោយបានរៀបចំសៀវភៅព្រឹត្តិបត្រព្រឹទ្ធសភា(ស្ទួន) ឆ្នាំ២០១២ ចំនួន៨២០ក្បាល ត្រួតពិនិត្យបញ្ចូលមាតិកាលិខិត និងមាតិកាសំណុំលិខិតទៅក្នុងប្រព័ន្ធកុំព្យូទ័រ ចំនួន១៦សំណុំលិខិត។

### ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន២២លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ លិខិតជូនពរ លិខិតអបអរសាទរ លិខិតថ្លែងអំណរគុណ

លិខិតរំលែកទុក្ខ និងកន្ត្រកផ្កា របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណាព្រះមហាក្សត្រ**នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី** ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងជូនឥស្សរជនជាន់ខ្ពស់ជាតិ-អន្តរជាតិ និងថ្នាក់ដឹកនាំតាមក្រសួង-ស្ថាប័ននានា ចំនួន៩១លិខិត និងចំនួន១៤កន្ត្រក។

- បានរៀបចំកំណត់បង្ហាញ រៀបចំឯកសារជំនួយស្មារតី រៀបចំលិខិតឆ្លើយតបជាភាសាអង់គ្លេស បកប្រែឯកសារ និងបានរៀបចំឯកសារផ្សេងៗ ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន៣១ច្បាប់/លើក។
- បានផលិត និងផ្សព្វផ្សាយ "ព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែមេសា ឆ្នាំ២០២៥" ចំនួន ១ច្បាប់ និង
- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន៥ច្បាប់។

**៤.៧-ការងារអគ្គាធិការដ្ឋានៈ**

- បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមេសា ឆ្នាំ២០២៥ ចំនួន២២លើក។
- បានប្រមូល និងរៀបចំរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋានស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានា របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានរៀបចំរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវា ប្រចាំខែមេសា ឆ្នាំ២០២៥។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែមេសា ឆ្នាំ២០២៥ ចំនួន២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមាន ដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមាន ប្រចាំថ្ងៃ ចំនួន៣៨លើក ប្រចាំសប្តាហ៍ ចំនួន៤លើក និងប្រចាំខែមេសា ឆ្នាំ២០២៥ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែឧសភា ឆ្នាំ២០២៥

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន២៦ច្បាប់៖

  ១- សេចក្តីព្រាងច្បាប់ស្តីពី ដលផល។

  ២-សេចក្តីព្រាងច្បាប់ស្តីពី ការទទួលខុសត្រូវលើផលិតផលមានវិការៈ និង

៣-សេចក្តីព្រាងច្បាប់ ចំនួន២៤ច្បាប់ ពាក់ព័ន្ធនឹងការអនុម័តយល់ព្រមលើការធានាទូទាត់របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាឱ្យក្រុមហ៊ុនអភិវឌ្ឍន៍នានា។

- ត្រៀមរៀបចំកិច្ចប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសិក្សាលើសេចក្តីព្រាងច្បាប់ ចំនួន២៦ច្បាប់។
- ត្រៀមប្រជុំផែនការថវិការបស់ព្រឹទ្ធសភា ឆ្នាំ២០២៦ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
- ត្រៀមរៀបចំសមាជរដ្ឋសភា និងព្រឹទ្ធសភា។

## ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការជាមួយក្រសួង-ស្ថាប័ន អាជ្ញាធរថ្នាក់ក្រោមជាតិ និងចុះបេសកកម្ម ដើម្បីតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ពិនិត្យវឌ្ឍនភាពនៃការអភិវឌ្ឍនៅថ្នាក់ក្រោមជាតិ ចូលរួមសិក្ខាសាលា វេទិកា កិច្ចប្រជុំនានា និងពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ** នៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជពិធីច្រត់ព្រះនង្គ័ល និងពិធីបុណ្យវិសាខបូជា និង
- ត្រៀមទទួលដំណើរទស្សនកិច្ចរបស់សាធារណជន និងសិស្ស និស្សិត ដើម្បីសិក្សាឈ្វេងយល់អំពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ត្រៀមផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
    - អញ្ជើញបំពេញទស្សនកិច្ច នៅសាធារណរដ្ឋឥណ្ឌូណេស៊ី និងសាធារណរដ្ឋប្រជាធិបតេយ្យទីម័រឡេស្តេ។
    - អញ្ជើញចូលរួមសិក្ខាសាលា ស្តីពី គោលនយោបាយអាកាសធាតុ នៅព្រះរាជាណាចក្រថៃឡង់ដ៏។
    - អញ្ជើញចូលរួមសិក្ខាសាលា ស្តីពី រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់សហភាពអន្តរសភា (IPU) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
    - អញ្ជើញចូលរួមកិច្ចប្រជុំបណ្តាញស្ត្រីសភា និងបណ្តាញសមាជិកសភាវ័យក្មេងនៃសភាប្រើភាសាបារាំង នៅខេត្តកេបិច ប្រទេសកាណាដា និង
    - អញ្ជើញចូលរួមព្រឹត្តិការណ៍បញ្ចាំងខ្សែភាពយន្តហ្វ្រង់កូហ្វូនលើកទី៣ នៅខេត្តសៀមរាប។
- បន្តត្រៀមស្រាវជ្រាវ បកប្រែ និងរៀបចំឯកសារជំនួយស្មារតី សុន្ទរកថាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបជាមួយភ្ញៀវអន្តរជាតិក្នុងជំនួបសវនាការ កិច្ចប្រជុំ និងទស្សនកិច្ចនានា។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញឌីជីថលចាំបាច់ (Essential Digital Skills) នៅវិទ្យាស្ថានឌីជីថល(IDG) នៃបណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថល (CADT)។
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី ជំនាញកត់ត្រា និងជំនាញសំខាន់ៗជាច្រើនទៀត។
- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន ទំនាក់ទំនងជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសេវាសំខាន់ៗផ្សេងទៀតជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ និង
- បន្តការចុះសួរសុខទុក្ខមន្ត្រីរាជការលំហែមាតុភាព និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## III-សេចក្តីសន្និដ្ឋាន

ខែមេសា ជាខែនៃការចាប់ផ្តើមសម័យប្រជុំលើកទី៣ នីតិកាលទី៥ របស់ព្រឹទ្ធសភា។ ស្របពេលជាមួយគ្នានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបើកសម័យប្រជុំលើកទី៣ នីតិកាលទី៥ របស់ព្រឹទ្ធសភា ដើម្បីស្តាប់របាយការណ៍សង្ខេបស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី២ និងលើកទី៣ នីតិកាលទី៥។

ចំពោះការងារការទូតសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានចូលរួមយ៉ាងសកម្ម ក្នុងការរៀបចំបដិសណ្ឋារកិច្ច និងជំនួបសវនាការ ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃឡង់ដ៍ និងឥស្សរជនជាន់ខ្ពស់នានា ទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋាន ក៏បានផ្តល់សេវាលើមុខងារតំណាង ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចុះជួបពិភាក្សាការងារ និងប្រាស្រ័យទាក់ទងជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គបោះឆ្នោត ទទួលបានលទ្ធផលគួរជាទីមោទនៈ ដែលជាគុណប្រយោជន៍រួមសម្រាប់ស្ថាប័ន និងប្រជាជន។

ក្រៅពីបំពេញការងារជូនស្ថាប័ន ក្នុងខែមេសានេះ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏ដូចជាប្រជាជនកម្ពុជាទាំងក្នុងប្រទេស និងក្រៅប្រទេស បានចូលរួមអបអរសាទរប្រារព្ធពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ ប្រព្រឹត្តទៅយ៉ាងអធិកអធមប្រកបដោយក្តីសប្បាយរីករាយក្រោមម្លប់សន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

ថ្ងៃព្រហស្បតិ៍ ៦ កើត ខែ ទុតិយាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០២៥

**អគ្គលេខាធិការ**

**ឡាយ សំគុល**